


**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៣៧

ក្នុងសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានបន្តស្តាប់សក្ខីកម្ម ស្តីពីការប្រព្រឹត្តលើជនជាតិវៀតណាម មុននឹងផ្អាកសវនាការដើម្បីឈប់សម្រាកបុណ្យណូអែលក្នុងរយៈពេលពីរសប្តាហ៍ខាងមុខ។ សប្តាហ៍នេះ បានផ្តើមស្តាប់សក្ខីកម្មអ្នកស្រី **ស៊ិន ឆែម** មានអាយុ៧៩ឆ្នាំ មកពីខេត្តស្វាយរៀង ដែលស្វាមីរបស់គាត់ជាមេឃុំក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មក អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សី **អ៊ី វុន** ដែលបានផ្តល់សក្ខីកម្មស្តីពីប្រធានដូចគ្នានឹងសាក្សីកាលពីសប្តាហ៍មុនគឺលោក **អ៊ុំ ស៊ន់** ពាក់ព័ន្ធនឹងការមើលឃើញ ដោយផ្ទាល់ភ្នែកពីការសម្លាប់ជនជាតិវៀតណាមជាច្រើន នៅវត្តខ្សាច់ដែលស្ថិតនៅភូមិយៀង ក្នុងឆ្នាំ១៩៧៨ ហើយរួមទាំងស្ត្រីម្នាក់ដែលមានឈ្មោះ **ចន្ថា** ផងដែរ។[1] ជាចុងក្រោយ សាក្សី **2-TCW-1000** បានផ្តល់សក្ខីកម្មស្តីពីព្រឹត្តិការណ៍នានានៅកោះតាង ហើយនិងការសម្លាប់រង្គាលលើជនជាតិភាគតិចវៀតណាម ដែលបានជាប់ឃុំនៅទីនោះ។ សាក្សីរូបនេះ បានផ្តល់សក្ខីកម្មដោយប្រើប្រាស់ឈ្មោះជារហស្សនាម ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេច ស្តីពីការរក្សាភាពសម្ងាត់របស់សាក្សីរូបនេះ ដែលត្រូវបានដាក់បញ្ចូលទៅក្នុង

[1] សម្រាប់ព័ត៌មានបន្ថែមស្តីពីសក្ខីកម្មរបស់សាក្សី **អ៊ុំ ស៊ន់** សូមមើលរបាយការណ៍ប្រចាំសប្តាហ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង០០២ វគ្គ២ លេខ ៣៦ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៣៣ (ចុះថ្ងៃទី៧ ដល់ ១១ ខែធ្នូ) ទំព័រ ៥ ដល់ ៦។

សំណុំរឿង០០២ វគ្គ២ ក្រោយពេលដែលមានការបើកកិច្ចស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង ០០៤។[2] ដំបូងឡើយ សាក្សី **2-TCW-1000** ត្រូវបានរៀបចំកាលវិភាគមកបង្ហាញខ្លួននៅចំពោះមុខតុលាការនៅដើមឆ្នាំ២០១៦ នេះ ក៏ប៉ុន្តែ ចាប់តាំងពីពេលដែលកាលវិភាគថ្មីសម្រាប់ការស្តាប់សក្ខីកម្មរបស់គាត់ត្រូវបានលើកទៅពេលវេលាក្រោយវិញ មេធាវីការពារក្តីបានស្នើសុំនូវពេលវេលាបន្ថែម ដើម្បីរៀបចំការសួរចេញដោលទៅសាក្សីនេះ។ ដូច្នេះហើយ សាក្សីនេះ បានបង្ហាញខ្លួនបានត្រឹមតែបីវគ្គនៃសវនាការក្នុងសប្តាហ៍នេះ ដែលត្រូវបានសួរដេញដោលដោយសហព្រះរាជអាជ្ញា និងមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។ រីឯមេធាវីការពារក្តីទាំងពីរក្រុម នឹងធ្វើការតាំងសំណួរដេញដោលសាក្សីរូបនេះ នៅពេលដែលអង្គជំនុំជម្រះបានបន្តកិច្ចដំណើរការនីតិវិធីសវនាការឡើងវិញនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ខាងមុខនេះ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ អាឡិចសាន់ឌើ បេនហ្ស (Alexander Benz), ជា ប៉ូរ៉ាក់មុន្នី, ម៉ាលេនី ហៃដ៍ (Melanie Hyde), គុំ សូមាលី, ខេតលីន កាហ្វព្រៀ (Caitlin McCaffrie), អេលីហ្សាប៊េត អ័រ (Elizabeth Orr), ធី ស៊ុន (Thi Son), តាយ លីណា, ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង ថាលីសា ហ្ស៊ឺ ហូសេន (Talisa zur Hausen) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និង យុត្តិធម៌អន្តរជាតិ (THE WSD HANDA Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

---

[2] អង្គជំនុំជម្រះសាលាដំបូង "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យទទួលយកឯកសារដែលទាក់ទិននឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៣ និង ០០៤" (ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤) លេខ E318/7 ។